# 11. កង់ នៃពហុធា - ការពង្រីក តាមពីជគណិត ហើយនិងការគិតមិនដល់ ( L'anneau des polynômes. Extensions algèbriques et transcendantes).

ចំពោះ លោកអ្នកសិក្សាអំពីពីជគណិត សញ្ញាណនៃពហុធា គឺជាប់ជំពាក់នឹងការសិក្សា អំពីអនុគមន៍ទេ ៖ ពហុធា ដែលមានអថេរតែមួយ គ្មានអ្វីក្រៅពីស្វីត មានចំនួនជាតុដល់ទៅអនន្ត $a_0, a_1, \dots\dots.., a_n$ យកក្នុងកង់ត្រលប់ A ហើយសូន្យចាប់ពីជួរណាមួយទៅ ។ គេថាពហុធាសូន្យ បើគ្រប់មេគុណស្មើនឹងសូន្យ ហើយពហុធាសូន្យនឹងតាងដោយ (0) ។

ពហុធាមួយ $P = (a_0, a_1, \dots\dots.., a_n)$ មានដឺក្រេ $(degré)$ យ៉ាងច្រើនស្មើនឹង $p$ ហើយចំពោះ $n > p$ គេបាន $a_n = 0$ ។ ហើយគេថាមានដឺក្រេ $p$ បើថែមលើនេះ $a_p \neq 0$ ដូច្នេះ ដឺក្រេនៃពហុធាមិនសូន្យ គឺ ចំនួនគត់ $p$ ដែលតូចជាងគេបំផុតបានបំពេញ ចំពោះ $n > p$ គេបាន $a_n = 0$ ។ ចំពោះ ពហុធាសូន្យ គេមិនមានកំណត់ដឺក្រេវាទេ តែគេអាចនិយាយថា ចំពោះចំនួនគត់ $n$ ណាក៏ដោយ ពហុធាសូន្យ មានដឺក្រេធំបំផុតត្រឹម $n$ ៖ ការសន្មតនេះធ្វើឲ្យងាយដល់ការថ្លែងនានា។

ពហុធាមួយដែលមានដឺក្រេយ៉ាងច្រើនស្មើនឹង $p$ គឺកំណត់ដោយស្វីតមិនអនន្ត $a_0, a_1, \dots\dots.., a_p$ នៃ $p+1$ ជាតុក្នុង $A$ ដោយត្រូវយល់ថា មេគុណទាំងឡាយបន្ទាប់ពី $a_p$ ទៅ សុទ្ធតែសូន្យ។ ពហុធានោះនឹងតាងជារូបរាងដោយ ៖

$$P(x) = a_0 + a_1 x + \dots + a_p x^p = \sum_{i=0}^{p} a_i x^i$$

ហើយគេ ជា ពហុធាមួយនៃអថេរ $x$ $(c'est\ polynôme\ de\ la\ variable\ x)$ ។ តែយើងមិនទាន់ប្រើការសរសេរនេះភ្លាមទេ ដរាបណាយើងមិនទាន់បានវែកញែកសម្ព័ន្ធរវាង សញ្ញាណអរូបីនៃពហុធា $(la\ notion\ abstraite\ de\ polynôme)$ និងសញ្ញាណនៃ អនុគមន៍ពហុធា$(la\ notion\ de\ fonction\ polynôme)$ ដែលយើងនឹងសិក្សា នៅពេល

ខាងមុខ ។

## ការបូក (*Addition*)

យើងតាងដោយ $P = (a_0, a_1, \dots\dots.., a_p)$ ពហុធាដែលមានដឺក្រេយ៉ាងច្រើនស្មើនឹង $p$ ហើយដោយ $Q = (b_0, b_1, \dots\dots.., b_q)$ ពហុធាដែលមានដឺក្រេយ៉ាងច្រើនស្មើនឹង $q$ និង $\sup(p, q)$ គឺចំនួនណាមួយដែលធំក្នុងចំណោម $(p, q)$ ។ ដូច្នេះ ចំពោះ $n > \sup(p, q)$ នោះគេបាន $a_n + b_n = 0$ ។ដូច្នេះ ស្វ៊ីត $a_n + b_n$ កំណត់នូវពហុធាដែលមានដឺក្រេយ៉ាងច្រើនស្មើនឹង $\sup(p, q)$ ។

តាមនិយមន័យ ពហុធាដែលមានមេគុណ (*coefficients*) $a_n + b_n$ ហៅថា បូកនៃ ពហុធា $P, Q$ ហើយតាងដោយ $P + Q$ ។

## ការគុណ (*Multiplication*)

ដោយយកការកត់ត្រាដដែល យើងតាង៖

(1) $c_n = a_0 b_n + a_1 b_{n-1} + \dots\dots. + a_k b_{n-k} + \dots\dots + a_n b_0 = \sum_{k=0}^{n} a_k b_{n-k}$

ចំពោះ $n > p + q$ នោះគេមាន $c_n = 0$ ដែលបង្ហាញថា ស្វ៊ីត $c_n$ កំណត់នូវពហុធាដែលមានដឺក្រេយ៉ាងច្រើនស្មើនឹង $p + q$ ។ តាមនិយមន័យ ពហុធានេះហៅថា គុណនៃ ពហុធា $P, Q$ ហើយតាងដោយ $PQ$ ។

ជាការងាយទេ ដែលបង្ហាញថា វិធីគណនា បូកនិងគុណ ដែលកំណត់ដោយនិយមន័យនេះ ធ្វើឲ្យសំនុំនៃពហុធាដែលមានមេគុណនៅក្នុង$A$នោះ មានរចនាសម្ព័ន្ធជា កងត្រលប់ (*une structure d'anneau commutatif*) ។ កង នេះគេតាងដោយ $A[x]$ ។

### ករណី $A$ ជាកងសុចរិត (*cas où A est un anneau d'intégrité*)

យើងត្រលប់មកការកត់ត្រាខាងលើវិញ ដោយឧបមាថា $P$ មានដឺក្រេ $p$ ហើយ $Q$ មានដឺក្រេ $q$ ហើយមេគុណ $c_n$ កំណត់ដោយរូបមន្ត (1)។ ដូច្នេះ គេបាន $c_{p+q} = a_p b_q$ ដោយ $a_p \neq 0$ និង $b_q \neq 0$ ដូច្នេះបើ $A$ ជាកងសុចរិត នោះ $c_{p+q} \neq 0$។ យើងអាចថ្លែងថា៖

## ***ការស្នើ*(V,11,1)**

***បើ A ជាកង់សុចរិត ការគុណនៃពហុធា P, Q មិនសូន្យ គឺមិនសូន្យ ហើយដឺក្រេរបស់វាស្មើនឹងផលបូកនៃដឺក្រេ នៃ ពហុធា P, Q ។***

***អនុសាព្យ (Corollaire)***

*បើ $A$ ជាកង់សុចរិត នោះ $A[x]$ក៏ជាកង់សុចរិតដែរ។*

*សង្កេត*

*បើ $A$ មានធាតុឯកតា តាងដោយ $1$ នោះកង់ $A[x]$ ក៏មានធាតុឯកតា ដែលជាពហុធាមានដឺក្រេសូន្យ កំណត់ដោយមេគុណ មិនសូន្យ $a_0 = 1$ ។*

*តែប៉ុន្តែបើ $A$ ជាអង្គក៏ដោយ ពហុធាដែលមានមេគុណក្នុង $A$ មិនផ្សំបានជាអង្គទេ[1] ។*

**អនុគមន៍ពហុធា (*Les fonctions – Polynômes*)**

*តាមពិត និយមន័យ នៃ ការបូកនិងការគុណ នៃពហុធា គឺបានដោយការសិក្សាអំពី អនុគមន៍ដែលត្រូវផ្គូនឹងពហុធានោះ ។*

*ពីពហុធា $P = (a_0, a_1, \dots\dots\dots, a_p)$ យើងអាចផ្គូនឹងអនុគមន៍ $\bar{P}$ ការអនុវត្តន៍ពី $A$ ទៅក្នុង $A$ ដដែល គំណត់ដោយ ៖ $\bar{P}(x) = a_0 + a_1 x + \dots + a_p x^p$ ហើយគេអាចពិនិត្យបញ្ជាក់ថា ការបូកនិងការគុណនៃពហុធា $P$ និង $Q$ ដែលបានកំណត់មកហើយនោះគឺដើម្បី ឲ្យអនុគមន៍ $\bar{R} = \overline{P+Q}$ និង $\bar{S} = \overline{PQ}$ ដែលផ្គូនឹង $R = P + Q$ និង $S = PQ$ នោះគឺជាផលបូកនិងផលគុណនៃ អនុគមន៍ $\bar{P}, \bar{Q}$ ។ បានន័យថា ៖ $\bar{R}(x) = \bar{P}(x) + \bar{Q}(x)$ និង $\bar{S}(x) = \bar{P}(x)\bar{Q}(x)$ ដែលគេបកស្រាយដោយ សមភាពជារូបនិមិត្ត ៖*

$$\overline{P+Q} = \bar{P} + \bar{Q} \quad \text{និង} \quad \overline{PQ} = \bar{P}\bar{Q} \quad ។$$

*តែបើគេកំណត់ ការបូកនិងការគុណនៃពហុធា ដោយយកអំពីការបូកនិងការគុណ*

[1] *ពីព្រោះធាតុមួយៗ គ្មានចំរាស ឧបមា $P(x) = 3x$ បើ $Q(x)$ជាពហុធាចំរាស នោះត្រូវ $P(x)Q(x) = 1$ => $Q(x) = \frac{1}{P(x)} = \frac{1}{3x} = \frac{1}{3}x^{-1}$ ប៉ុន្តែបើ $\frac{1}{3} \in A$ តែចំពោះ $x^{-1}$ ចំនួន $-1$ មិននៅក្នុង $N$ ទេ ។*

នៃអនុគមន៍ដែលផ្ទួនោះវិញ គេនឹងជួបនូវការលំបាកដ៏ខ្លាំង៖ តើការឲ្យអនុគមន៍ $\bar{P}$ អាចកំណត់បានពហុធា $P$ ឬទេ ? គឺថាការអនុវត្តន៍ $P \rightarrow \bar{P}$ ពីសំនុំនៃពហុធា ទៅសំនុំនៃការអនុវត្តន៍ពី $A$ ទៅ $A$ នោះអាំងសេចទីវឬទេ? បើសិនជាមិនអាំងសេចទីវទេនោះ ពហុធា $P+Q$ និង $PQ$ នឹងមិនកំណត់បានដោយគ្រប់គ្រាន់ដោយរូបមន្ត ៖

$$\overline{P+Q}\,(x) = \bar{P}(x) + \bar{Q}(x) \quad \text{និង} \quad \overline{PQ}\,(x) = \bar{P}(x)\,\bar{Q}(x)$$ ។

តែគេឃើញដោយងាយថា ចម្លើយមិនជាវិជ្ជមានតែគ្រប់ពេលនោះទេ ៖ ឧបមាបើ $A$ ជាកងដែលមានតែ 2 ធាតុ គឺថ្នាក់នៃសំណល់ម៉ូឌុយឡូ 2 (មើល §7) នោះ អនុគមន៍-ពហុធា $x(x+1) \equiv 0$ [2] (កុងគ្រុយ នឹង សូន្យ ម៉ូឌុយឡូ 2) ពីព្រោះ ក្នុងផលគុណ នៃចំនួនពីរជាប់គ្នា $x$ និង $x+1$ មានចំនួនណាមួយជាចំនួនគត់គូ (un nombre pair) ដូច្នេះ ចែកដោយ 2ដាច់ គឺថាសំណល់ស្មើនឹងសូន្យ។ ដូច្នេះ ពហុធា $P_1 = (0,1,1)$ និង ពហុធា $P_2 = (0)$ ទាំងពីរនេះ ផ្ទួនឹង អនុគមន៍-ពហុធា $\bar{P}(x) = x(x+1)$ ។ នេះមកតែពីមាន តួចែកនៃសូន្យ(diviseur de zéro) នៅក្នុងឧទាហរណ៍នេះ ។

តែត្រូវដឹងថា ចំពោះពហុធាធម្មតាដែលយើងធ្លាប់ប្រើនោះ (គឺមេគុណនៅក្នុង $Z, Q, R, C$) ពហុធាទាំងនោះសុទ្ធតែអាចកំណត់បានដោយ អនុគមន៍ដែលផ្ទួទាំងអស់ដោយចេញមកពី ទ្រឹស្តីបទ ជាទូទៅខាងក្រោមនេះ៖

## ការស្មើ(V,11,2)

**គេឲ្យ $A$ ជាកងសុចរិត (anneau d'intégrité) មានធាតុច្រើនដល់អនន្ត ហើយ $P$ និង $Q$ ជាពហុធាដែលយកមេគុណក្នុង $A$ នៅពេលនោះ សមភាពនៃអនុគមន៍ $\bar{P}$ និង $\bar{Q}$ ដែលផ្ទួនឹងពហុធានោះ បណ្តាលឲ្យមានសមភាព រវាង ពហុធានោះ ឬដោយ រូបនិមិត្ត ៖**

$$(\bar{P} = \bar{Q}) \Rightarrow (P = Q)$$ ។

## ការសង្កេតដំបូង

បើយើងតាង $R = P - Q$ យើងបាន $\bar{R} = \bar{P} - \bar{Q}$ ហើយយើងគ្រាន់តែបង្ហាញថា ទំនាក់ទំនង $\bar{R}(x) = 0$ ដែលត្រូវចំពោះគ្រប់ $x \in A$ => $R(x) = (0)$ ដោយតាង $(0)$ ជាពហុធា ដែលមានមេគុណទាំងអស់សុទ្ធតែសូន្យ ឬ ដោយសរសេរជា រូបនិមិត្ត

$\forall x \in A,\ \bar{R}(x) = 0 \quad => \quad R(x) = 0$

បើយើងហៅថា « សូន្យ » នៃពហុធា $R$ គឺជាតួ $x \in A$ ដែលឲ្យ $\bar{R}(x) = 0$ នោះ កម្មសិទ្ធិនេះចេញមកពី សម្មតិកម្មលើ $A$ និង ទ្រឹស្តីបទដូចតទៅនេះ ៖

**<u>ការស្នើ(V,11,3)</u>**

***បើ $A$ ជាកងសុចរិត ពហុធាមួយមានដឺក្រេ $n$ ហើយយកមេគុណក្នុង $A$ មានយ៉ាងច្រើន $n$ «សូន្យ» ខុសពីគ្នា ។***

យើងនឹងបង្ហាញការស្នើនេះ ក្នុងករណីដែល $A$ មានធាតុឯកតា $e$ មួយ ដោយ សន្មតថាគេអាចបានករណីនេះដោយពង្រីក $A$[2] ។ ការបង្ហាញចែកជាបីដំណាក់។

I. យើងតាងដោយ $P$ ពហុធាមានដឺក្រេយ៉ាងច្រើន $n$ ហើយកំណត់ដោយមេគុណ $a_0, a_1, \ldots\ldots, a_n$ និង $c$ ជាធាតុមួយនៃ $A$ ។

យើងដាក់ ៖ $b_n = a_n$ , $b_{n-1} = a_{n-1} + ca_n$ ហើយជាទូទៅចំពោះ $0 \le p \le n$

(1) $b_p = a_p + ca_{p+1} + c^2a_{p+2} + \ldots + c^r a_{p+r} + \ldots + c^{n-p}a_{p+n-p}$ (តួចុងគេនេះគឺ $c^{n-p}a_n$)

ហើយយើងតាងដោយ $Q$ ពហុធាមានដឺក្រេយ៉ាងច្រើន $n-1$ ហើយកំណត់ដោយមេគុណ $b_1, b_2, \ldots\ldots, b_n$ ។ បើយើងតាងដោយ $(x - c)$ ពហុធាមានដឺក្រេ មួយ ហើយ

[2] បើ $A$ ជាកងសុចរិត គេអាចប្រើរបៀបពង្រីកលើ $A$ ដើម្បីឆ្លងពី $Z \to Q$ ដោយជាដំបូងគេ ធ្លុះ $A$ (symétriser $A$) ចំពោះលេខគុណ ។ ហើយដល់បាន សំនុំថ្មី $K$ ហើយ គេក៏ពង្រីក $K$ ដោយលេខ បូកដែលមាននៅលើ $A$ ។ ហើយគេក៏ប្រើរបៀបនេះចំពោះ $A$ ដែលគ្មានធាតុឯកតា៖ គឺថាគេអាចពង្រីក កង $A$ សុចរិត ដែលគ្មានធាតុឯកតា ឲ្យបានជា កងសុចរិតមួយថ្មីដែលមានធាតុឯកតា ។

មេគុណ $(-c, 1)$ និង $b_0$ [3] ពហុធា (សូន្យ ឬ ដឺក្រេសូន្យ) កំណត់ដោយ មេគុណតែមួយគត់ $b_0$ នោះដោយធ្វើលេខជម្ពូតាយើងអាចពិនិត្យបញ្ជាក់ សមភាព ៖

(2) $P = (x-c)Q + (b_0)$ [4]

II. យើងបាន : $b_0 = a_0 + a_1c + \dots\dots + a_pc^p + \dots\dots + a_nc^n = \bar{P}(c)$[5]

ដោយ ទំនាក់ទំនង (2) យើងអាចថ្លែង ការស្មើដូចតទៅនេះ៖

**ទ្រឹម $(V, 11, 4)$**

ដើម្បី ពហុធា $P$ ចែកដាច់ដោយពហុធា $(x-c)$ នោះគ្រាន់តែ $c$ ជា « សូន្យ [6] » នៃ $P$ ហើយ ដូច្នោះ ផលចែកនៃ $P$ ដោយ $(x-c)$ គឺ ពហុធា $Q$ ដែលមានដឺក្រេ តូចជាងមួយ ឯកតា បើធៀបទៅនឹងដឺក្រេនៃ $P$ ។

III. បើ ពហុធា $P$ មានចំនួន $n$ « សូន្យ » ខុសៗគ្នា $c_1, c_2, \dots\dots, c_n$ នោះទ្រឹម $(V, 11, 4)$ យកមកអនុវត្តទៅលើ $P$ និង $c_1$ អាចឲ្យយើងអាស់អាងថាមាន ពហុធា $Q_1$ដែលមាន ដែលមានដឺក្រេ $(n-1)$ យ៉ាងច្រើន ដែលឲ្យ $P = (x - c_1)Q_1$ ហើយបើ $A$ មិនមានតួចែកនៃសូន្យទេនោះ ទំនាក់ទំនង៖

$\bar{P}(c_k) = (c_k - c_1)\,\overline{Q_1}(c_k) = 0 \Rightarrow \overline{Q_1}(c_k) = 0$ ចំពោះ $k \geq 2$

ដោយ ប្រើជាថ្មី ទ្រឹម $(V, 11, 4)$ យកមកអនុវត្តទៅលើ $Q_1$ និង $c_2$ យើងឃើញថា $Q_1$ ចែកដាច់នឹង $(x - c_2)$ ហើយផលចែកគឺ ពហុធា $Q_2$ មានដឺក្រេ $n-2$ យ៉ាងច្រើន ដែលមាន $c_3, \dots\dots, c_n$ ជា « សូន្យ » ។ ហើយដោយជិតបន្តិចម្តងៗ (ដោយរ៉េគារ៉ង់មិនអនន្ត) គេក៏បង្ហាញថា $P$ ចែកដាច់ដោយ ការគុណនៃកត្តា $(x - c_1)(x - c_2)\dots.(x - c_n)$ ហើយផលចែកចុងក្រោយ $Q_n$ គឺពហុធា សូន្យឬ មានដឺក្រេសូន្យ កំណត់ដោយមេគុណតែមួយ

---

[3] បានដោយ ឲ្យ $p = 0$ នៅក្នុង (1)

[4] ដើម្បីបាន ទំនាក់ទំនងនេះ យើងគ្រាន់តែ ធ្វើលេខគុណ រវាង ពីរពហុធា ដោយ $Q = (b_1, b_2, \dots\dots, b_{n-1})$

[5] មើលនិយមន័យ អនុគមន៍ពហុធា $\bar{P}(x)$ ហើយ (2) ទៅជា $P = (x-c)Q + \bar{P}(c)$

[6] « សូន្យ »តាមការសន្មតខាងលើ គឺថា $\bar{P}(c) = 0$

គត់ $a_n$ ។ ដូច្នេះយើងឃើញថា ពហុធា $P$ ពុំអាចមាន «សូន្យ» $c_{n+1}$ ខុសពី $c_1, \ldots, c_n$ ហើយមិនស្មើនឹងសូន្យនោះទេ (គឺថា បើមាន $c_{n+1}$ នោះ $c_{n+1} = 0$ )។

បើ $A$ ជាកង់សុចរិត មានធាតុដល់អនន្ត យើងអាច សម្គាល់ ពហុធាដែលយកមេគុណក្នុង $A$ ថាដូចគ្នានឹង អនុគមន៍-ពហុធា ដែលធ្វើឲ្យការសិក្សាទៅជាងាយបំផុត។

នៅគ្រប់ករណី យើងអាចសម្គាល់ ពហុធាដឺក្រេសូន្យ ដោយមេគុណតែមួយគត់ ៖ ពីព្រោះថា បើយើងតាងដោយ $(a)$ ពហុធាដឺក្រេសូន្យមានមេគុណ $a$ យើងឃើញថា ការអនុវត្តន៍ $a \to (a)$ កំណត់ អ៊ីសូមោហ្វីស ពី $A$ ទៅ សំនុំនៃពហុធាទាំងនោះ ។ គេក៏អាចសម្គាល់ ពហុធា $(a)$ ទៅនឹងចំនួនមិនប្រែប្រួល $a$ (អនុគមន៍ យកចំនួន $a$ ជានិច្ច ) ។ ដូច្នេះ « កង់ពហុធា យកមេគុណក្នុង $A$ » ជា « កង់ $A$ ដែលពង្រីកតាមពីជគណិត » ។

<u>សមីការពីជគណិត ( *Equations algèbriques*)</u>

គេហៅថា សមីការពីជគណិត លើកង់ $A$ គឺទំនាក់ទំនងមានរាង $\bar{P}(x) = 0$ ដោយ $P$ ជាពហុធាយកមេគុណក្នុង $A$ ។ ចំនួន សូន្យនៃ $P$ ហៅថាសូន្យ ឬ រឹស នៃសមីការ ៖ គឺជាតុនៃ $A$ ដែលផ្ទៀងផ្ទាត់សមីការ ។

ត្រូវប្រយ័ត្នថា សំនុំនៃសូន្យ ជាប់ទាក់ទងនឹង កង់ ដែលគេដាក់ ៖ ដូចជា សមីការ $x^2 = 2$ មិនមានរឹសនៅក្នុងអង្គ $Q$ នៃចំនួនសនិទាន តែមានរឹសនៅក្នុងអង្គ $R$ នៃចំនួនពិត។ សមីការ $x^2 + 1 = 0$ មិនមានរឹសនៅក្នុង $R$ តែមានរឹស នៅក្នុងអង្គ $C$ នៃចំនួនកុំផ្លិច។

ទ្រឹស្តី នៃអនុគមន៍ មានអថេរកុំផ្លិច (*fonctions de variable complexe*) អាចឲ្យទ្រឹស្តីបទជាគ្រឹះមួយហៅថា ទ្រឹស្តីបទអាឡំបែរ ( *théorème d'Alembert*) ដូចតទៅនេះ៖

ពហុធាមានដឺក្រេ $n \geq 1$ យកមេគុណក្នុង $C$ មាន សូន្យ យ៉ាងហោចណាស់មួយនៅក្នុង $C$។

ដោយប្រើឡឹមដែលបានបង្ហាញរួចមកហើយ គេអាចទាញយកដោយថ្ងៃថា ៖ គ្រប់ ពហុធា មានដឺក្រេ $n$ អាចបំបែកជា $n$ កត្តាគុណ ដោយកត្តានីមួយៗមានតែ មួយដឺក្រេ (*Tout polynôme de degré n se décompose en un produit de n facteurs*

$du\ premier\ degré)$ ។

======================== **ចប់ ជំពូក** $V$ =======================